# កិច្ចសំភាសន៍របស់អ៊ុំស្រីឈ្មោះ សិន រឹម

កៈ អ្នកសំភាសន៍ឈ្មោះ ហោង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ សិន រឹម

កៈ ចាសជាដំបូងសូមជំរាបសួរអ៊ុំស្រី?

ខៈ ចាស ខ្ញុំសុំនិយាយតាំងពីខ្ញុំដឹងវ៉យមក....

កៈ ចាសអ៊ុំ!

ខៈ ចាស....

កៈ
ចាសអ៊ុំចឹងថ្ងៃនេះខ្ញុំសុំនិយាយទាកទងជាមួយនឹងអឺ....ការណែនាំគឺពួកខ្ញុំទាំងអស់គ្នាគឺមកពីសាលា BYU ហាវ៉ៃ
ពួកខ្ញុំបានធ្វើការស្ម័គ្រចិត្តនឹងធ្វើការនៅក្នុងគំរោងរបស់សាលាហើយថ្ងៃនឹងអឺ....ខ្ញុំមានឪកាសដើម្បីនឹងសំភាសន៍អ៊ុំផ្ទាល់ទាកទងជាមួយនឹងប្រវត្តិហើយអឺ....ជីវៈភាពរបស់អ៊ុំស្រីផ្ទាល់ជាពិសេសបទពិសោធន៍របស់អ៊ុំដែលអ៊ុំទទូលបានតាំងពីអ៊ុំស្រីនៅក្មេងរហូតដល់ពេលដែលអ៊ុំចាសនឹងថាអ៊ុំធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍អីខ្លះ
ហើយខាងសាលាគេចង់យកសំលេងរបស់អ៊ុំនឹងយកទៅដាក់នៅក្នុងវេបសាយរបស់សាលាដើម្បីអោយកូនចៅជំនាន់ក្រោយគេបានស្តាប់
ចឹងថ្ងៃនេះផងដែរក្មួយមានសំណាងមែនទែនដែលបានមកសំភាសន៍ជាមួយនឹងអ៊ុំស្រីផ្ទាល់ចឹងអ៊ុំស្រីអាចអនុញ្ញាតអោយខ្ញុំដាក់ហើយនឹងអឺ....ថតសំលេងរបស់អ៊ុំស្រីចូលទៅក្នុងវេបសាយដែរឬទេអ៊ុំស្រី?

ខៈ ចាស (សំលេងរំខានពីខាងក្រៅ)
ខ្ញុំតាំងពីក្មេងមកខ្ញុំមិនគួរណាឪពុកខ្ញុំម្តាយខ្ញុំនៅនឹងស្រុកនឹងដល់ពេលនេះទៅគាត់ក្រគាត់ទៅនៅនឹងចំការកៅស៊ូ ខាងមេមត់ណាស់(សំលេងរំខានពីខាងក្រៅ) !

កៈ ចាសអ៊ុំ!

ខៈ ខាងមេមត់ នឹងហើយ ដល់ទៅៗ ខ្ញុំអាយុ១២ឆ្នាំអីនឹងឪពុករបស់ខ្ញុំនឹងបានស្លាប់ចោល!

កៈ ចាសអ៊ុំ!

ខ៖
ចាសដល់ពេលដែលឪពុកខ្ញុំស្លាប់ចោលទៅម្ដាយខ្ញុំយកខ្ញុំទៅអោយស៊ីឈ្នួលគេនៅភ្នំពេញ!

ក៖ ចាសៗអ៊ុំ!

ខ៖ មុនបែកលន់នលនោះ(សំលេងរំខានពីខាងក្រៅ)
អោយមកស៊ីឈ្នួលគេទៅភ្នំពេញហើយគាត់មកបើកប្រាក់ខែរបស់ខ្ញុំនឹងអស់
ហើយម្ដាយខ្ញុំមករស់នៅៗនឹងចំការកៅស៊ូនឹង!

ក៖ អឺម!

ខ៖
ដល់តែពេលនេះទៅទទួលបានបែកពីភ្នំពេញនឹងវ៉ៃបែកអឺ....ស្ពានជ្រោយចង្វានេះ(សំលេងរំខានពីខាងក្រៅ)
ក៏បងខ្ញុំទៅយកមកវិញទៅយកមកនឹងទៅនៅនឹងចំការកៅស៊ូវិញដល់នេះទៅបានប្រហែលពីរបីខែខ្ញុំក៏ត្រឡប់មកវិញ(សំលេងរំខានពីខាងក្រៅ)ត្រឡប់មកនៅនឹងភ្នំពេញវិញ
អានេះបងខ្ញុំនឹងគាត់ទៅយកខ្ញុំត្រឡប់មកវិញ!

ក៖ ចាសអ៊ុំ!

ខ៖ ទៅយកទៅមកដល់ត្រឹមស្ពន់កំពង់ចាមនេះបានខ្ញុំឆ្លងមកផ្ទះម៉ែខ្ញុំនៅព្រៃវែង!

ក៖ ចាសអ៊ុំ ចឹងជាដំបូងខ្ញុំសុំសួរឈ្មោះរបស់អ៊ុំសិទៅណាស់អ៊ុំ តើអ៊ុំស្រីមានឈ្មោះអីដែរ?

ខ៖ ខ្ញុំឈ្មោះ សិន រឹម!

ក៖ ចាសអ៊ុំហើយចុះឈ្មោះរបស់អ៊ុំនឹងត្រូវនឹងអត្តសញ្ញាណប័ណ្ណដែរឬទេអ៊ុំ?

ខ៖ ចាសត្រូវនឹងអត្តសញ្ញាណប័ណ្ណ!

ក៖ ត្រូវៗពេញម៉ងន៍អ៊ុំន៍?

ខ៖ ចាសត្រូវពេញ!

ក៖ ហើយចុះអ៊ុំស្រីឆ្នាំនឹងអ៊ុំមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំអាយុ៦៣ឆ្នាំ!

កៈ ៦៣ឆ្នាំហើយន៍អ៊ុំ?

ខៈ ចាស!

កៈ ចាសអ៊ុំស្រី ហើយចុះអ៊ុំមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែរឬទេ?

ខៈ ចាំខ្ញុំកើតនៅឆ្នាំមមែ!

កៈ ឆ្នាំមមែ ចុះថ្ងៃណាដែរអ៊ុំស្រី?

ខៈ ថ្ងៃខ្ញុំអត់ចាំទេកូន(សំលេងរំខានពីខាងក្រៅ)!

កៈ ចាស ហើយចុះឆ្នាំ?

ខៈ ឆ្នាំមមែ!

កៈ អឺ.....ឆ្នាំ....

ខៈ មមែ....

កៈ ឆ្នាំជាលេខណាស់អ៊ុំ?

ខៈ ចាស?

កៈ ឆ្នាំជាលេខណាស់អ៊ុំ ១៩០០ប៉ុន្មានដែរអ៊ុំ?

ខៈ អត់ដឹងទេ!

កៈ
អឺ....ហើយចឹងអ៊ុំមានចាំថាអ៊ុំកើតថ្ងៃខែឆ្នាំកំណើតត្រូវជាថ្ងៃខែឆ្នាំកំណើតខ្មែរយើងណាស់ដូចជាមិខគសិ ខាងសុរិយគតិអីណាស់អ៊ុំមាននៅចាំដែរឬទេ?

ខៈ អត់ចាំទេកូន!

កៈ ចាសអ៊ុំ ហើយចុះអ៊ុំសព្វថ្ងៃមានទីលំនៅៗឯណាដែរ?

ខៈ ខ្ញុំនៅនឹងកោះឧកញ៉ាតី!

កៈ ចាសនៅក្នុងខេត្តកណ្តាលន៍អ៊ុំន៍?

ខៈ ចាសនៅខេត្តកណ្តាល!

ក៖ ចាសអ៊ុំ ហើយចុះអ៊ុំកាលពីមុនអ៊ុំធ្លាប់រស់នៅឯណាដែរអ៊ុំ?

ខ៖ ខ្ញុំធ្លាប់នៅ....រស់នៅខាងត្នោតម្លប់ខាងខេត្តព្រៃវែង(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំស្រី!

ខ៖ ស្រុក....ត្នោតម្លប់ខេត្តព្រៃវែង!

ក៖ ចាសអ៊ុំ ចឹងអ៊ុំស្រីផ្លាស់ទីលំនៅពីនោះមកណេះ?

ខ៖ ផ្លាស់....ចាសផ្លាស់ទីលំនៅមករស់នៅនឹងនេះវិញ!

ក៖ ចឹងរយះពេលប៉ុន្មានឆ្នាំហើយដែរអ៊ុំបានផ្លាស់ទីលំនៅមកនៅនឹង?

ខ៖ ចូលម្ភៃឆ្នាំជាងហើយ!

ក៖ អូ...ចាសអ៊ុំស្រី ចឹងយូរដែរហើយន៍អ៊ុំស្រី?

ខ៖ ចាស!

ក៖ ចាសហើយចុះអ៊ុំសព្វថ្ងៃអ៊ុំមានក្រុមគ្រួសារដែរឬទេ?

ខ៖ ខ្ញុំអត់មានទេប្តីរត់ចោលបាត់ហើយ!

ក៖ គាត់មានឈ្មោះអីដែរអ៊ុំប្តីរបស់អ៊ុំស្រីនឹង?

ខ៖ ឈ្មោះ ម៉ាក់ ឡាំផា(សំលេងរំខានពីខាងក្រៅ)!

ក៖ អូ.....មូលហេតុអីបានជាគាត់រត់ទៅចោលអ៊ុំចឹងណាស់អ៊ុំ? ទុកអោយអ៊ុំនៅតែម្នាក់ឯង?

ខ៖ គាត់មានស្រី(សំលេងរំខានពីខាងក្រៅ)!

ក៖ អូ....យូរឆ្នាំឬនៅអ៊ុំ?

ខ៖ ប៉ុន្មានប្រហែលជា១២ឆ្នាំហើយ(សំលេងរំខានពីខាងក្រៅ)!

ក៖ យូរដែរហើយន៍អ៊ុំ?

ខ៖ ចាស!

ក៖ ចាសអ៊ុំហើយចុះអ៊ុំមានកូនដែរឬទេ?

ខ៖ ខ្ញុំមានកូន៩នាក់(សំលេងរំខានពីខាងក្រៅ)!

ក៖ អូ....កូនច្រើន!

ខ៖ ចាស!

ក៖ ចាសហើយចុះអ៊ុំមានចាំឈ្មោះកូនរបស់អ៊ុំម្នាក់ៗដែរទេអ៊ុំ?

ខ៖ ខ្ញុំចាំមីទីមួយឈ្មោះ ថា សារួន!

ក៖ ចាសអ៊ុំស្រី!

ខ៖ ទីពីរឈ្មោះ ថា ធី!

ក៖ ចាសអ៊ុំស្រី!

ខ៖ ទីរបីឈ្មោះ ថា រិន (សំលេងស៊ីផ្លេឡាន)!

ក៖ ចាសអ៊ុំស្រី!

ខ៖ ទីបួនឈ្មោះ ថា.....

គ៖ ទីបី ថា សារ៉ែត(សំលេងកូនក្មេងពីខាងក្រៅ)!

ខ៖ ទីបីឈ្មោះ ថា សារ៉ែនៗ!

ក៖ អឺម....

ខ៖ ទីបួន ថា រិន(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំស្រី!

ខ៖ ទីប្រាំឈ្មោះ ថា ធន់!

ក៖ ចាសអ៊ុំស្រី!

ខ៖ទីប្រាំមួយឈ្មោះ....(សំលេងស៊ីផ្លេឡានពីខាងក្រៅ) ថា ធារ៉ា!

ក៖ ចាសអ៊ុំស្រី!

ខ៖ អឺម....ទីប្រាំពីរឈ្មោះ ថា....អេ...ថា....ធន់ ហើយ ថាៗហើយទីប្រាំបីៗ ស្រីប៉ាន់(សំលេងរំខានពីខាងក្រៅ) ហើយទីប្រាំបួនឈ្មោះ ថា ស្រីកែវ!

កៈ ចាសអ៊ុំស្រីហើយកូនរបស់អ៊ុំនឹងស្រីប៉ុន្មានប្រុសប៉ុន្មានដែរទៅអ៊ុំស្រី?

ខៈ ប្រុសប្រាំ....

កៈ ចឹងស្រីបួន!

ខៈ ស្រីបួន....ចាស!

កៈ ចាសអ៊ុំស្រី ហើយចុះពួកគាត់រៀបអាពាហ៍ពិពាហ៍ប៉ុន្មានហើយអ៊ុំ?

ខៈ នៅសល់តែពីរនាក់ទេ!

កៈ អូ....ចឹងរៀបការអស់ហើយអស់រហូតទៅដល់ប្រាំពីរនាក់ហ៎!

ខៈ ចាសៗ!

កៈ នៅសល់តែពីរនាក់ទេ!

ខៈ ចាសនៅសល់តែពីរនាក់ទេ!

កៈ ចាសចុះកូនរបស់អ៊ុំរៀបអាពាហ៍ពិពាហ៍ទាំងអស់អ៊ុំមានចៅៗហើយឬនៅអ៊ុំ(សើច)?

ខៈ (សើច) មានចៅៗនឹងជាង១០នាក់ហើយ!

កៈ (សើច) អូ....បានច្រើនណាស់!

ខៈ ចាស!

កៈ មានចៅទួតដែរឬទេអ៊ុំស្រី?

ខៈ នៅអត់ទាន់មានទេ!

កៈ នៅទេអ៊ុំន៏?

ខៈ ចាសនៅទេ!

កៈ
ហើយអឺ....ពួកគាត់ទាំងអស់គ្នាមានទីលំនៅៗម្តុំៗនឹងដែរឬក៏ពួកគាត់ទៅនៅផ្សេងៗពីគ្នាតាមខេត្តឬក៏ទីក្រុង?

ខៈ នៅ....តាមខេត្តកំពង់ចាម នៅខេត្តកំពង់ឆ្នាំង!

កៈ អឹម....

ខៈ ចាស!

កៈ តែពីរខេត្តនឹងទេន៍អ៊ុំស្រី?

ខៈ ចាសបើម្នាក់ទៀតនៅជិតនឹងទេ!

កៈ ចាសអ៊ុំស្រី ហើយទៅពួកគាត់មកលេងនឹងអ៊ុំដែរឬទេ?

ខៈ មកលេងតើ!

កៈ ចូលឆ្នាំអីនឹងពួកគាត់មកលេងន៍អ៊ុំ?

ខៈ ចាសមក!

កៈ ទាំងចៅទាំងអីនឹងមកលេងសប្បាយជុំគ្នា!

ខៈ ចាស សុទ្ធតែចៅហើយនោះ!

កៈ អូ....ចាសអ៊ុំស្រី!

ខៈ ចៅ១១នាក់១២នាក់ហើយចៅ!

កៈ ចាសអ៊ុំស្រី (សំលេងរំខានពីខាងក្រៅ)
ហើយអឺ....អ៊ុំស្រីសព្វថ្ងៃអ៊ុំរស់នៅប៉ុន្មានអ្នកដែរ(មានសំលេងរំខានពីខាងក្រៅ)?

ខៈ
ខ្ញុំនៅផ្ទាល់នឹងសព្វថ្ងៃនឹងនៅជាមួយនឹងកូនស្រីពៅនឹងកូនប្រុសច្បងមួយ(សំលេងរំខានពីខាង
ក្រៅ)!

កៈ ចាសអ៊ុំស្រី ហើយទៅអ៊ុំស្រីមានបងប្អូនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ និយាយទៅខ្ញុំសព្វថ្ងៃនឹងខ្ញុំនៅតែពីរនាក់នឹងទេ!

កៈ ចាសអ៊ុំស្រី ហើយចឹងសព្វថ្ងៃអ៊ុំស្រីនៅតែពីរនាក់បងប្អូននឹងទេ?

ខៈ ចាស!

កៈ ពួកគាត់មានឈ្មោះអីខ្លះទៅអ៊ុំ?

ខ៖ ឈ្មោះ.....(មានសំលេងរំខានពីខាងក្រៅ) ខ្ញុំមានបងប្អូនបីនាក់ ខ្ញុំមួយហើយនឹងកូនខ្ញុំមួយឈ្មោះរី ហើយនឹងម្នាក់ទៀតឈ្មោះពៅ!

ក៖ ចាសអ៊ុំស្រីចឹង(សំលេងរំខានពីខាងក្រៅ) ពួកគាត់សព្វថ្ងៃនៅជាមួយអ៊ុំស្រីន៏អ៊ុំត្រូវហ្អែសអ៊ុំ?

ខ៖ អត់ទេ នៅនឹងឯស្រុកមួយហើយមួយទៀតនឹងធ្វើការនៅនឹងភ្នំពេញ!

ក៖ តែពួកគាត់តែពួកគាត់ធ្វើការហើយមកស្នាក់នៅជាមួយនឹងអ៊ុំនឹងហ្អែសអ៊ុំ?

ខ៖ អត់ទេ!

ក៖ អត់ទេន៏អ៊ុំ(សំលេងរំខានពីខាងក្រៅ) ចាសចឹងបងប្អូនមានបីនាក់តែអត់បានរស់នៅជុំគ្នាទេ?

ខ៖ អត់ទេ!

ក៖ ចាសអ៊ុំស្រី ហើយអឺ....អ៊ុំស្រីឪពុកម្តាយរបស់អ៊ុំគាត់....

ខ៖ ស្លាប់អស់បាត់ហើយ!

ក៖ ស្លាប់បាត់អស់ហើយគាត់ស្លាប់នៅក្នុងជំនាន់ពលពតឬក៏គាត់ស្លាប់ដោយសារជំងឺដែរអ៊ុំ?

ខ៖ គាត់ស្លាប់ដោយសារជំងឺ!

ក៖ ក្រោយអាពតឬក៏មុនអាពតដែរអ៊ុំគាត់ស្លាប់នឹង?

ខ៖ គាត់....ឪពុកខ្ញុំស្លាប់មុនអាពតមួយហើយម្តាយរបស់ខ្ញុំគាត់ស្លាប់ពេលដាច់អាពតហើយនឹង!

ក៖ អឺម....ចាសហើយទៅអ៊ុំមាននៅចងចាំដែរឬទេថាកាលនឹងពួកគាត់ស្លាប់ដោយសារជំងឺអីដែរអ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លាប់ដោយសារជំងឺរបស់គាត់នឹងម៉ងលើសឈាមនឹង ហើយឪពុកខ្ញុំស្លាប់ដោយសារគាត់វង្វេងចូលក្នុងព្រៃ!

ក៖ អូ...ចាស!

ខ៖ គាត់វង្វេងចូលទៅក្នុងព្រៃចំការកៅស៊ូនឹងព្រៃធំ(សំលេងរំខានពីខាងក្រៅ)!

កៈ នៅខេត្តណាដែរអ៊ុំ?

ខៈ នៅខាងចំការកៅស៊ូហ៎!

កៈ ចំការលើហ៎?

ខៈ មេមត់ន៏!

កៈ អ...មេមត់ហ៎?

ខៈ នឹងមេមត់នឹង!

កៈ ចាស បាត់ដំណឹងគាត់ម៉ង?

ខៈ ចាសគាត់ចូលទៅក្នុងព្រៃ ដល់តែពេលដែលគេរកឃើញៗនៅតែដៃហើយត្រឹមខ្លួន ក អីនឹងបាត់អស់រកអត់ឃើញរកឃើញតែប៉ុន្នឹង!

កៈ អឺម!

ខៈ នៅសល់តែប៉ុន្នឹង!

កៈ គេមកប្រាប់អ៊ុំហ៎អ៊ុំ?

ខៈ ចាស គាត់ស្លាប់នៅក្នុងព្រៃ!

កៈ អូ....សោកស្តាយមែនទែនចាស!

ខៈ ចាស!

កៈ កាលនឹងជំនាន់ដាច់អាពតហើយឬក៏ម៉េចដែរអ៊ុំ? ជំនាន់ដាច់....

ខៈ នៅទេ(សំលេងរំខានពីខាងក្រៅ)!

កៈ នៅមិនទាន់ចូលអាពតទេន៏អ៊ុំស្រី?

ខៈ នៅទេ!

កៈ នៅមិនទាន់ចូលអាពតទេនៅសម័យលន់នលនៅឡើយ?

ខៈ នឹងហើយ!

ក៖ ចាស អើយអ៊ុំអើយ! ហើយកាលនឹងអ៊ុំអី...បាត់ឪពុកម្ដាយនឹងកាលនឹងអ៊ុំអាយុប៉ុន្មានឆ្នាំដែរ?

ខ៖ ខ្ញុំកាលនឹងនៅតូចនឹង មិនទាន់សូវដឹងអីផងនៅតូចដែរ!

ក៖ ប្រហែលជាដប់ឆ្នាំជាងហ៎អ៊ុំ?

ខ៖ នឹងហើយ!

ក៖ ចាសក្នុងខ្ទង់ប៉ុន្នឹងន៍? ចុះពេលដែលអ៊ុំ....

ខ៖ អត់ទាន់ដល់អាយុ១០ឆ្នាំទេឪពុកខ្ញុំស្លាប់នឹង!

ក៖ ចាស អូ...ចុះនៅពេលដែលបែកពីឪពុកម្ដាយហើយអ៊ុំបីនាក់បងប្អូននឹងអ៊ុំស្រីទៅណាដែរកាលនឹង?

ខ៖ ទៅស្រុកៗវិញ!

ក៖ ស្រុកកំណើតអ៊ុំនៅ....?

ខ៖ ព្រៃវែង!

ក៖ នៅព្រៃវែងនឹងម៉ង?

ខ៖ ចាស!

ក៖ ចុះអ៊ុំធ្វើយ៉ាងណាដើម្បីអី...(សំលេងកូនក្មេងក្អក) ដូចថាចិញ្ចឹមបងប្អូនណាស់?

ខ៖ (សំលេងរំខានពីខាងក្រៅ) បងប្អូននឹងនាំគ្នាចិញ្ចឹមម្ដាយចឹងទៅ!

ក៖ អូ....

ខ៖ ម្ដាយខ្ញុំឈឺរហូតតាំងពីឪពុកខ្ញុំនឹងគាត់បានស្លាប់ចោលទៅនឹង!

ក៖ ចាស!

ខ៖ ចាស គាត់អត់អាចធ្វើអីបានទេហើយខ្ញុំចេះតែនាំបងប្អូននឹងនាំគ្នារកចិញ្ចឹមម្ដាយរហូតចឹងចិញ្ចឹមបងប្អូននឹងទៅ!

កៈ ចាសអ៊ុំ
ចាសចឹងកាលនឹងអ៊ុំអឺ....(សំលេងរំខានពីខាងក្រៅ)ដូចថាអ៊ុំខ្លួនឯងនឹងណាស់ធ្វើអឺ...ការងារអីគេដើម្បីចិញ្ចឹមដល់ពួកគាត់នឹងណាស់ពីព្រោះថាពួកគាត់ចាស់ជរាអស់ទៅហើយណាស់?

ខៈ គាត់នៅចំការកៅស៊ូធ្វើការគាត់មានមេចាស់ហ៎ គាត់មានលេខធ្វើការ!

កៈ ចាស!

ខៈ ចាសមានលេខធ្វើការខ្ញុំអាយុ(សំលេងរំខានពីខាងក្រៅ)
ប្អូនដប់ឆ្នាំអីនឹងខ្ញុំទៅជំនួសដៃរបស់គាត់ដូចគាត់ធ្វើផ្ទះពេទ្យចឹងទៅយើងគ្រាន់តែទៅធ្វើការបោសសំអាតនៅផ្ទះពេទ្យនឹងទៅដូចស្មោរស៊ីរាំងស្មោរអីចឹងទៅនៅកន្លែងពេទ្យនឹងហើយបោសសំអាតនៅកន្លែងពេទ្យអីចឹងទៅជំនួសលេខរបស់គាត់ណាស់(អ៊ុំស្រីគាត់ទៅធ្វើការជំនួសអោយម្តាយរបស់គាត់)!

កៈ ចាស!

ខៈ ចាសដើម្បីអោយម្តាយគាត់បានឈប់នឹងទៅក៏ចេះតែទៅធ្វើទៅ ចាស!

កៈ ចាសអ៊ុំស្រី ហើយអ៊ុំកាលនឹងអឺ...ខ្ញុំសុំសួរបកកាលពីជំនាន់ការរបស់អ៊ុំណាស់
កាលនឹងអ៊ុំទាន់សម័យអាពតដែរឬទេអ៊ុំកាលនឹង?

ខៈ ខ្ញុំទាន់ដែរតើ!

កៈ កាលនឹងអ៊ុំអាយុប៉ុន្មានឆ្នាំហើយ?

ខៈ កាលនឹងខ្ញុំអាយុ២០ ម្ភៃជាងហើយ!

កៈ ចាស កំពុងពេញកំលាំងហើយន៍អ៊ុំន៍?

ខៈ ចាស!

កៈ ហើយគេជំលៀសអ៊ុំទៅណាដែរ?

ខៈ ខ្ញុំនៅនឹងស្រុកនឹងទេ ខ្ញុំនៅនឹងស្រុកនឹងប៉ុន្តែគេអោយទៅធ្វើការ
គេអោយទៅរែកដីអីចឹងទៅណាស់!

កៈ ចាស!

ខ៖ វែងដីប្រព័ន្ធភ្លឺស្រែអីនឹងទៅវែង កាប់ដីវែកប្រព័ន្ធភ្លឺស្រែនឹង!

ក៖ អូ...ពិបាកណាស់កាលនឹងចឹង!

ខ៖ ចាសវែកដី(សំលេងរំខានពីខាងក្រៅ) វែកដីលើប្រព័ន្ធភ្លឺស្រែនឹងខ្ញុំវែក កាប់ដីវែកនឹងយកទៅ កាប់ដីវែកនឹងទៅដូចគេផ្សាយនៅក្នុងទូរទស្សន៍នឹង!

ក៖ អឺម!

ខ៖ វែកដីនឹង ហើយបើយើងឈឺថ្កាត់ឈឺល្មមៗអីនឹងគេថាយើងនឹងពត់ទន្សាយ(ធ្វើពត់)!

ក៖ អឺម!

ខ៖ ចាសគេថាយើងនឹងពត់ទន្សាយ!

ក៖ អឺម...ហើយកាលនឹងគេមានធ្វើបាបអ៊ុំដែរឬទេអ៊ុំ?

ខ៖ គេអត់ធ្វើបាបអីយើងទេ ប៉ុន្តែគ្រាន់តែថាយើងស៊ីនឹងមិនពេញលេញ ស៊ីតែបបរនឹងទៅបបររហូតបបរនឹងហើយទៅយើងកំលាំងស្រីនោះហើយទៅយើងត្រូវកាប់ដីនោះយើងម៉េចនឹងដូចគេមនុស្សប្រុស!

ក៖ ហើយអ៊ុំអើយ!

ខ៖ ចាស!

ក៖ គេអោយអ៊ុំវែកនឹងប៉ុន្មានបង្គីរប៉ុន្មាន....

ខ៖ ច្រើនណាស់កូនអើយគេវាស់ម៉ែត្រដូចយើងថាហ៎ តម្រូវលើកអោយបានប៉ុន្មានម៉ែត្រ១០ម៉ែត្រចឹងទៅវែកប៉ុន្មាននាក់បួនទៅប្រាំអ្នកចឹងទៅវែកអោយបានពេញប៉ុណ្ណឹងមក!

ក៖ អឺម!

ខ៖ ចាស!

ក៖ គេដាក់កំណត់អោយយើងចឹង!

ខ៖ ចាស!

ក៖ ចុះបើសិនជាយើងធ្វើមិនបានអ៊ុំ?

ខ៖ ធ្វើអត់បានគេអត់ព្រមគេពិន័យយើង ចឹងគេយកយើងទៅកសាង!

ក៖ អូ....ចឹងអ៊ុំធ្លាប់ដែលគេព្រមានដែរឬទេ(សំលេងរំខានពីខាងក្រៅ)?

ខ៖ ធ្លាប់ៗ!

ក៖ ធ្លាប់ហ៎អ៊ុំ? ចាសគេម៉េចខ្លះទៅអ៊ុំ?

ខ៖ គេថាយើងធ្វើម៉េចក៏ដោយអោយតែបានគ្រប់ចំនួនអោយគេ(សំលេងរំខានពីខាងក្រៅ)!

ក៖ ហើយទៅខំធ្វើទៅ!

ខ៖ ខំទៅទោះបីជាយើងអត់អីយ៉ាងណាក៏ខំប្រឹងធ្វើរហូតទៅ
ដល់ធ្វើដល់ម៉ោង១១ចឹងទៅយើងមកស៊ីបាយមកស៊ីបាយហើយម៉ោង....អត់ដល់ម៉ោងមួយផង
គេអោយយើងចុះទៀត!

ក៖ អឺម!

ខ៖ ចុះទៅទៀតនឹងត្រឹមម៉ោងបួនដល់ម៉ោងប្រាំយើងចេញ(សំលេងរំខានពីខាងក្រៅ)
បានយើងចូលមកហូបបាយ
ហូបហើយល្ងាចហើយទៅកាប់ដីទៀតកាប់ដីរហូតដល់ម៉ោង១០អីនឹងបានគេអោយយើងសំរា
ក!

ក៖ អឺម!

ខ៖ ចាសនឹង!

ក៖ ហ៊ើយអ៊ុំអើយ ហើយចឹង....

ខ៖ គេប្រើយើងកុំអោយមានពេលសំរាកមានពេលស៊ីចឹងណាស់(សំលេងស៊ីផ្លេម៉ូតូឡាន)!

ក៖ ចាស!

ខ៖ គេជៀសវា ព្រោះវាសំលាប់ស្រស់ៗម៉ង!

ក៖ អូ... អ៊ុំធ្លាប់ឃើញអាពតយកមនុស្សទៅសំលាប់ដែរឬទេ?

ខ៖ ធ្លាប់ឃើញដែរ ធ្លាប់ឃើញគេចាប់អ្នកដែលមានទោសមានអីនឹងណាស់
ឃើញគេយកទៅវៃនឹង(សំលេងរំខានពីខាងក្រៅ)!

កៈ អឺម!

ខៈ
ស្នាយពុលៗខ្ញុំធ្លាប់ទៅឃើញនឹង(សំលេងរំខានពីខាងក្រៅ)អោយតែវាបើកម៉េក្រូអានឹងវាសម្លាប់ហើយនៅពេលយប់នឹងថ្ងៃនឹងវាអត់ទាន់ដល់ហើយពួកនឹងវារត់ពេញទាំងអី...ស្នាយពុលនឹង(សំលេងរំខានពីខាងក្រៅ) រត់ទៅដល់ពេលតែរត់ចឹងទៅវាចាប់បានអ្នកណាវាសំលាប់អ្នកនឹងដូចអ្នកដែលបណ្តើរគ្នានៅតាមផ្លូវអីនឹងអោយតែពួកវាឃើញពួកវាចាប់ឃើញជាក់ស្តែងមែនកូនអើយ
មនុស្សចាស់នឹងវាសម្លាប់ហើយអាកូនតូចនឹងវាលើកជំពុះទង់នឹងបោះទៅលើកជំពុះទង់នឹងលើកពីក្រោមទ្រមក!

កៈ អឺម...អ៊ុំបានឃើញហ៎?

ខៈ ចាស ឃើញចាស!

កៈ អាណោចអាធ័មមែនទែន!

ខៈ ចាសឃើញ
បើដូចគេយកទៅសំលាប់អីចឹងទៅឃើញក្មេងចឹងតូចចូលចឹងទៅវាចេះវាណាស់គេសម្លាប់ម្តាយងាប់ទៅ កូននឹងគ្នាមិនទៅបៅម្តាយទៅបៅម្តាយនឹងបៅទាំងឈាមទាំងអីនឹង
រួចកូននឹងគេចាក់នឹងជំពុះទង់នឹងងាប់ទៀតទៅ!

កៈ អូ...អាណោធអាធ័មណាស់អ៊ុំអើយ!

ខៈ មួយស្នាយពុលនឹងគឺអណ្តូងពេញទាំងអស់ មានតែអណ្តូងពីរ បីទេអោយផឹកនឹង
ក្រៅពីនឹងអណ្តូងពេញៗទាំងអស់ហើយមានជីករណ្តៅទៀតនៅតាមមាត់ស្ទឹងអីនឹងសុទ្ធតែឆ្អឹងខ្មោចទាំងអស់(សំលេងរំខានពីខាងក្រៅ) ស្នាយពុលនឹង!

កៈ ចាស ជិះពីនឹងទៅឆ្ងាយដែរទេអ៊ុំស្នាយពុលនឹង?

ខៈ ឆ្ងាយដែរ ស្នាយពុលនឹង!

កៈ ប្រហែលជាមួយគីឡូ ពីរគីឡូអីនឹងហ៎?

ខៈ យី...ឆ្ងាយណាស់កូនមិនមែនមួយគីឡូពីរគីឡូទេ!

កៈ ចាស!

ខ៖ ឆ្ងាយណាស់!

ក៖ ចាស នៅត្រង់កន្លែងនឹងឥលូវគេធ្វើអីដែរអ៊ុំ វាលស្រែ?

ខ៖ ឥលូវនឹងគេធ្វើស្ពានហើយ(សំលេងម៉ូតូរំខាន)
ឥលូវគេធ្វើស្ពានស្រួលបួលហើយពីមុននឹងវាដាច់ស្ពាននឹងហើយវាចងសម្លាប់នឹងស្ពាននឹងម៉ង
!

ក៖ អូ...

ខ៖ ចងសម្លាប់នៅនឹងគល់ស្ពាននឹងកាលសម័យអាពតនឹងណាស់!

ក៖ ចាសអឺម ចាសចឹងឥលូនកន្លែនឹងសព្វថ្ងៃគេ....

ខ៖ គេបើកផ្សារហើយ!

ក៖ គេដាក់កន្លែងបូជាហ៍អ៊ុំ?

ខ៖ អត់ កន្លែងនឹងគេធ្វើផ្សារឡើងស្អាត(សំលេងស៊ីផ្លេម៉ូតូ) ស្អាតណាស់(ស្តាប់មិនបានច្បាស់)!

ក៖ ចឹង?

ខ៖ ចាសគេបង្កើតផ្សារធំណាស់!

ក៖ អឹម!

ខ៖ ចាស នៅនឹងមាត់ស្ទឹងនឹង!

ក៖ ចឹង? តែអឺ...សាកសពទាំងអស់នឹងអ៊ុំមានបានដឹងថាគេយកទៅណាដែរទេអ៊ុំ?

ខ៖ អត់ដឹងថាគេយកទៅណាអស់ទេ ឆ្អឹងអីនឹងមិនដឹងថាគេយកទៅណាអស់ហើយទេ!

ក៖ អឹម!

ខ៖ ខ្ញុំមិនដឹងដែរ(សំលេងម៉ូតូរំខាន)!

ក៖ ចាស អួយហើយកាលនឹងអ៊ុំស្រីមានសំណាងមែនទែនដែលអ៊ុំនៅមានជីវិត?

ខ៖ ហើយសំណាងណាស់កូនអើយ ហើយខ្ញុំកូនខ្ទីមីបងនឹងណាស់
នៅពេលជិតចប់នឹងណាស់គេជីករណ្តៅក្រឡឹងទាំងស្រុកអស់

ពេញទាំងជុំវិញភូមិចឹងណាស់(សំលេងស៊ីផ្លេម៉ូតូ) នេះ
យប់ឡើងវាបាញ់គ្នាព្រួសប្រាសចឹងទៅហើយកាលនឹងខ្ញុំទើបតែកូនខ្ចីទើបនឹងបានទំលាក់ច
ង្ក្រាន្តនោះ(សំលេងរំខានពីខាងក្រៅ)បីកូនរត់ចូលទៅក្នុងរណ្ដៅត្រង់ស្រុកនឹងកាលកំណើតមីប
ងនឹង(សំលេងកូនក្មេង) បីកូនរត់ចូលរណ្ដៅត្រង់ស្រុកឆ្នាំអាពេលជិតចប់នឹង
នៅស្រុកនឹងណាស់ត្នោតមាសនឹង!

ក៖ អឹម! កាលនឹងសម័យអីគេដែរអ៊ុំ?

ខ៖ សម័យអាពតនឹង!

ក៖ មិនមែនសម័យលន់នលទេហ៍អ៊ុំ?

ខ៖ សម័យអាពតនឹង អាពេលដែលយួនវាចូលមកនឹង!

ក៖ អូ....ចឹងកាលនឹងគេមានទំលាក់គ្រាប់បែកដែរហ៍អ៊ុំ?

ខ៖
មានណាស់កាលនឹងហើយទំលាក់គ្រាប់បែកៗគ្រាន់តែយន្តហោះងឿងចឹងស្ដាប់ទាន់ហើយរត់
ចូលទៅក្នុងរណ្ដៅត្រង់សេទៅ
ព្រោះភូមិខ្ញុំមួយនឹងវាទំលាក់គ្រាប់បែកនឹងមកត្រូវចំផ្ទះគេមួយនោះប៉ុន្តែវាអត់ចេះផ្ទុះមួយទំហឹ
ងចឹងស្រុតចុះទៅក្រោមប្រហែលជា៦០ម៉ែត្រចុះទៅក្រោមនឹង(សំលេងរំខានពីខាងក្រៅ)
គ្រាប់អាធំណាស់អត់ផ្ទុះ!

ក៖ អឹម! ចេះអត់អីដែរ!

ខ៖ ចេះអត់អី
ទើបតែ៨០ស្រួលបួលបានគេពួកកងទ័ពអីនឹងគេទៅគាស់យកមកទៅគ្រាប់នឹងកាលនឹងណា
ស់(នៅឆ្នាំ១៩៨០ពួកកងទ័ពបានទៅគាស់យកគ្រាប់នោះមក) នឹងចឹងណាស់!

ក៖ ចាស!

ខ៖ ចាស!

ក៖ ចាសអ៊ុំ ហើយកាលជំនាន់ពលពតនឹងវេទនាមែនទែនអ៊ុំ?

ខ៖ វេទនាណាស់កូន!

ក៖ ចាសហើយទៅគេអោយអាហារអ៊ុំមួយថ្ងៃប៉ុន្មានដងដែរ?

ខ៖ មួយថ្ងៃបីដងដែរនឹង ប៉ុន្តែមិនមានបានបាយអីទេបានតែបបរនឹងបបរនឹងទៅ!

ក៖ បបររហូតនឹងម៉ងហ៎អ៊ុំ?

ខ៖ ចាសបបររហូតនឹង!

ក៖ ចុះអ៊ុំអឺ...ដូចថាញុំអត់ឆ្អែតចឹងអ៊ុំធ្លាប់លួចញុំដែរឬទេអ៊ុំ(សំលេងរំខានពីខាងក្រៅ)?

ខ៖ ធ្លាប់ដែរប៉ុន្តែខ្ញុំបានម្តាយគាត់នៅផ្ទះ
ម្តាយគាត់នៅផ្ទះចឹងទៅគាត់គេចែករបបអោយចឹងណាស់មួយថ្ងៃមួយកំប៉ុងៗចឹងទៅហើយខ្ញុំក៏បានហូបជាមួយនឹងម្តាយនៅនឹងផ្ទះនឹងខ្លះទៅ!

ក៖ ចាសអ៊ុំ!

ខ៖ គាតពិសារអត់អស់ទេមួយកំប៉ុងនឹងនោះ!

ក៖ អូ....

ខ៖ ចាសបានមនុស្សចាស់នៅនឹងផ្ទះ!

ក៖ ចាសហើយកាលនឹងគេមានរបបរួមន៍អ៊ុំត្រូវហ្អែស?

ខ៖ មានរបបរួម!

ក៖ តែយើងអាចយកមកអោយខាងម្តាយ....

ខ៖ អត់បានទេ!

ក៖ អត់បានទេហ៎?

ខ៖ យកអត់បានទេកូន
សូម្បីតែត្រីចាប់បានតែពីស្រែយកមកនឹងក៏អត់បានយកមកផ្ទះយើងដែរ ចាស!

ក៖ ចាសអ៊ុំ
នៅពេលកាលនឹងអ៊ុំមានធ្លាប់លួមបេះផ្លែឈើឬក៏ដំណាំអីយកមកញុំដែរឬទេអ៊ុំកាលនឹង?

ខ៖ ខ្ញុំអត់ទេអត់ហ៊ានលួចអីគេទេ!

កៈ អ៊ុំអត់ហ៊ានបេះទេ!

ខៈ អត់ហ៊ានទេកូន!

កៈ ចុះអ៊ុំមានដែរឈឺទេអ៊ុំបើញុំអត់ឆ្អែងចឹង? ឈឺដែរហ៎....

ខៈ ឈឺដែរ(សំលេងរំខានពីខាងក្រៅ)ប៉ុន្តែឈឺនឹងរុះរាន់ប្រញាប់ឆាប់ទៅសុំថ្នាំអោយហើយលេបអោយហើយទៅ!

កៈ ចាស ត្រូវហើយអ៊ុំ!

ខៈ ហើយថ្នាំនឹងមិនដឹងថាដូចថ្នាំស្អីទេដូចថ្នាំ អំពុកស្អីទេ
គេធ្វើជាគ្រាប់ៗចឹងទៅដូចថ្នាំចំណាំងឈើចឹងណាស់ ចត់ៗនឹងថ្នាំគេនឹង!

កៈ អឹម!

ខៈ មិនទៅបានថ្នាំល្អអី!

កៈ យកមកដាំទឹកហ៎អ៊ុំ?

ខៈ ដាំទឹកអីយកមកទំពារលេបទឹកនឹង ចឹងយើងរុះរាន់សុំគេលេបអោយហើយចឹងទៅណាស់!

កៈ ចាសអ៊ុំ ហើយកាលនឹងអ៊ុំឈឺអីគេខ្លះទៅ?

ខៈ ដូចថាក្តៅស្រៀវអីនឹង ឈឺក្បាលវិលមុខអីតិចតួចយើងចេះតែខំប្រឹងលេបទៅ ចាស!

កៈ អូ...ចឹង!

ខៈ ចាស!

កៈ អឹម ចឹងកាលនឹងពិបាកដែរ ហើយអ៊ុំឈឺច្រើន!

ខៈ ចាស!

កៈ តែកាលនឹងអ៊ុំអត់ដែលទៅពេទ្យ គេអត់អោយអ៊ុំទៅពេទ្យទេន៏អ៊ុំ?

ខៈ អត់ទេ!

កៈ គ្រាន់តែទៅពេទ្យសុំថ្នាំលេបនឹងទៅ?

ខ៖ សុំថ្នាំលេប…ចាស សំណាងល្អ
សំណាស់ល្អណាស់កូនអើយបានមានជីវិតរស់នៅនឹងបើខ្ញុំឃើញគេ(សំលេងរំខានពីខាងក្រៅ) ឃើញគេក្អួយខ្ញុំវាឈឺវាពោគស្ត្រីណាស់វាចុកវាទៅៗពេទ្យគ្រាន់តែបានតែមួយសន្ទុះស្លាប់បណ្តោយ!

ក៖ អឺម!

ខ៖ យើងធ្វើការធ្ងន់ណាស់!

ក៖ ចាស!

ខ៖ ពោគស្ត្រីយើងនឹងវាចុកពេលមក(ពេលមករដូវ) ធ្វើការចឹងយើងធ្វើការងារធ្ងន់ចឹងណាស់!

ក៖ ចាសអ៊ុំស្រី!

ខ៖ វែកដីមិនស្រួលឯណាយើងជាស្រីយើងកាប់ដីទៅយើងវែកទៅ
ម៉េចនឹងដូចគេមនុស្សប្រុសដល់ពេលដែលយើងមករដូវទៅវាចុកវាចាប់នឹង(សំលេងម៉ូតូរំខាន) យកទៅពេទ្យបានមួយភ្លែតក៏នឹងស្លាប់!

ក៖ អូយ! អ៊ុំអើយ!

ខ៖ រួចបើម្តាយខ្ញុំវិញឈឺចឹងគេយកទៅពេទ្យម្តាយខ្ញុំឈឺនឹង
ហើយខ្ញុំយកទៅពេទ្យគេអោយយកមកពេទ្យព្រែកលួង ព្រែកចាស់នេះ
ខ្ញុំគេអត់អោយជិះរទេះសេះសោះ ខ្ញុំសុខចិត្តរត់តាមរទេះសេះណាស់
រត់ហើយទាល់តែផុតភូមិនឹងប្រហែលជា១០គីឡូដីបានគេអោយខ្ញុំជិះអោយចជិះរទេះសេះនឹង ខ្ញុំតាមរហូតដល់នេះទៅបានមកដល់ព្រែកចាស់នឹងបានគេអត់អោយខ្ញុំទ្រាំទៀតទេគេអោយខ្ញុំទៅផ្ទះទៅ
ចាសនៅពេលដែលខ្ញុំមកផ្ទះបានតែមួយយប់ម្តាយខ្ញុំផ្តាំថាអោយកូនរបស់ខ្ញុំមកយកខ្ញុំផង ព្រោះគេឃើញៗគេឈឺដែលនៅក្បែរគាត់នឹងព្រលឹមឡើងគេបូមទឹកៗនឹងណាស់យកទៅចាក់មួយសន្ទុះប្រកាច់ងាប់ភ្លាម!

ក៖ អឺម!

ខ៖ ម៉ែខ្ញុំនឹងគាត់ឃើញផ្ទាល់ភ្នែកនឹងម៉ង
ម៉ែខ្ញុំគាត់ឃើញផ្ទាល់ភ្នែកឃើញបូមស៊ីរ៉ាំងចឹងទៅអត់មានបូមថ្នាំទេបូមទឹកៗហើយយកទៅចា

ក់អោយហើយដល់ពេលតែចាក់ហើយតែមួយភ្លែតនឹងប្រកាច់ងាប់នឹងម៉ែខ្ញុំគាត់គ្រាន់តែឃើញតែប៉ុណ្ណឹងគាត់ស្លន់គាត់ណាស់គាត់ផ្តាំអោយខ្ញុំទៅយកគាត់អោយកូនខ្ញុំមកយកខ្ញុំទៅផ្ទះខ្ញុំទៅផ្ទះវិញផង(សំលេងរំខានពីខាងក្រៅ) គាត់ផ្តាំមកចឹងណាស់
ហើយខ្ញុំជិះកង់មកយកម្តាយខ្ញុំរហូត
វិហារសួគ៌នេះពីៗត្នោតមកវិហារសួគ៌នេះជិះកង់មកយកម្តាយខ្ញុំត្រឡប់មកវិញអត់កើតទេ
បើគ្នាប្រកាច់ប្រកិនចឹងស្រាប់តែរួចទៅបូមទឹកចាក់មើលឃើញនឹងភ្នែកទាំងស្រស់ៗចឹងកូនអើយម៉ែខ្ញុំគាត់ឃើញហើយរួចរំលងបានប៉ុន្មានថ្ងៃក៏កូនបងជីដូនមួយខ្ញុំនឹងក៏ចុកទៀតចុកហើយក៏ទៅពេទ្យទៀត(សំលេងរំខានពីខាងក្រៅ) ចូលពេទ្យនឹងទៀតគាត់ក៏ស្រែកទឹកដូង
ស្រែកទឹកដូងក៏អោយប្តីនឹងទៅយកមកផ្ទះទ្រាំអត់បានទេទៅយកមកផ្ទះគ្រាន់តែមកយកដូងត្រឡប់ទៅវិញគេយកប្រពន្ធទៅកប់បាត់ហើយគាត់មានទៅឈឺអីទេគ្រាន់តែចុកតែប៉ុណ្ណឹង(សំលេងរំខានពីខាងក្រៅ)!

ក៖ អឹម!

ខ៖ ចាសដូចយកទៅអោយគេសំលាប់ ហើយទៅក៏ស្លាប់បាត់!

ក៖ ចាស អ៊ុំ....

ខ៖ ថាសម្លាប់នឹងស្រស់ៗពេកហើយកូន!

ក៖ ចាសហើយចុះអ៊ុំកាលនឹងមានបងប្អូនស្លាប់នៅក្នុងជំនាន់អាពតដែររទេអ៊ុំ?

ខ៖ មាន បងខ្ញុំបង្កើតនឹងពីរនាក់!

ក៖ អឹម!

ខ៖ បងបង្កើតពីរនាក់ បងប្រុសមួយធ្វើទាហ៊ានមួយៗ
មួយទៀតគាត់ធ្វើមេកាលីសៀងនៅភ្នំពេញនឹងខាងរទេះភ្លើងណាស់(សំលេងរំខានពីខាងក្រៅ)
!

ក៖ ចាស!

ខ៖ រួចដល់នេះទៅគេជំលៀស(សំលេងម៉ូតូរំខាន)
គេជំលៀសគាត់ទៅខាងស្ទន់កំពង់ចាមនេះក៏ដើរទៅនឹង(សំលេងម៉ូតូរំខាន)
ដល់ពេលនេះទៅគាត់ដើរអត់រួចប្រពន្ធផងកូនផងកូនរបស់គាត់ច្រើននោះប្រាំពីរ

ប្រាំបីនាក់ហើយប្រពន្ធពោះធំប៉ុន្មានខែដើរអត់រួចដើរទៅកំពង់ចាមនឹង(សំលេងកូនក្មេងរំខាន) ដើរអត់រួចទៅស្ទួន់កំពង់ចាមនឹងនឹងណាស់គាត់ក៏សំរាកនៅនឹងៗមិនបានប៉ុន្មានថ្ងៃផងគេយកទៅសំលាប់អស់ទាំងកូនទាំងចៅទាំងម្ដាយក្មេកទាំងអស់អត់មាននៅសល់ម្នាក់ទេស្លាប់ទាំងអស់បងរបស់ខ្ញុំនឹងធ្វើទាហាននឹងគាត់ធ្វើកងទ័ពខាងរំដោះនឹងណាស់នឹងគាត់ធ្វើខាងនឹងណាស់ទៅអង្គភាពគេប្រមូលទៅខាងអង្គភាព ប្រមូលទៅខាងអង្គភាពអត់ទៅទេខ្លាចគេយកទៅវៃចោលដល់នេះឪពុកម៉ាចេះតែហៅទៅមកហ្នាទៅៗ
បានជាគ្នាទៅទាំងអស់គ្នាបានតែសុខចិត្តទៅនឹង
ទៅបានតែមួយយប់គេចងវៃងាប់អស់មកពីខាង
....មកពីលើវិញមកណាស់កូនអើយចងទាំងខ្សែៗសុទ្ធតែកងទ័ព!

កះ អឺម!

ខះ គេចងគាត់ក៏ស្លាប់ត្រឹមកន្លែងស្ពាយពុលនឹង!

កះ អឺម! ចាសអ៊ុំ
ចុះនៅពេលដែលបងប្អូនរបស់ស្លាប់នឹងអ៊ុំមានឃើញគេសម្លាប់ពួកគាត់ផ្ទាល់ដែរឬទេអ៊ុំ?

ខះ ខ្ញុំអត់បានឃើញផ្ទាល់
ប៉ុន្តែគេយកគាត់ទៅពីល្ងាចចឹងព្រឹកឡើយខ្ញុំមកៗយកគេយកមកកន្លែងផ្ទះរបស់គេសំណាក់ដែលគេថាយកគាត់មកនៅនឹងៗណាស់
នៅជាមួយនឹងណាស់ហើយទៅខ្ញុំដើរគាត់អត់ឃើញសោះ!

កះ អឺម!

ខះ
បានមកដល់ស្ពាយពុលទៀតខ្ញុំក៏សុំគេចូលទៅមើលបងខ្ញុំសុទ្ធតែយោធាមកមួយបន្ទប់នឹងសុំគេទៅរកមើលបងមនុស្សមួយបន្ទប់នឹងសុំគេទៅចូលទៅសល់ពេលចូលទៅមើលអត់ឃើញបងរបស់ខ្ញុំឃើញសុទ្ធតែគេអ្នកដទៃយប់ឡើងកូនអើយគេសម្លាប់គ្នាអស់!

កះ ចាសអ៊ុំ អឺម....អ៊ុំហើយចឹងឪពុកម្ដាយរបស់ពួកគាត់មានឈ្មោះអីដែរទៅអ៊ុំ?

ខះ ឈ្មោះ(សំលេងរំខានពីខាងក្រៅ) ឪពុករបស់ខ្ញុំគាត់ឈ្មោះ សិន!

កះ ចាសអ៊ុំ!

ខ៖ ចាស ម្ដាយរបស់គាត់ឈ្មោះ លី កិត!

ក៖ ចាស កិត
ពេលគេជំលៀសទៅនឹងជំលៀសទៅទាំងគ្រួសារឬក៏ជំលៀសទៅកន្លែងតែមួយអុំ?

ខ៖ ទៅកន្លែងតែមួយ(សំលេងរំខានពីខាងក្រៅ)!

ក៖ តែន៎អុំចឹងយើងអាចស្គាល់ដូចទៅណាទៅណីបានជុំគ្នាន៎អុំន៎?

ខ៖ ចាស!

ក៖ ធ្វើការធ្វើអីនឹងបាននៅជុំគ្នានៅជាមួយគ្នាដែរ?

ខ៖ ចាស!

ក៖ ចឹងបានជាអុំដឹងរឿងច្រើន ចាស
ហើយអឺ....កាលនឹងអុំមានចងចាំអ្វីជាងគេនៅក្នុងជីវិតរបស់អុំដែលតាំងពីមុនរហូតមកដល់ឥលូវនឹងអុំអត់អាចបំភ្លេចបានសោះណាស់អុំកាលនឹង?

ខ៖
រឿងដែលមិនអាចនឹងបំភ្លេចបាននឹងកូនគឺនៅពេលដែលឪពុកម្ដាយរបស់ខ្ញុំពួកគាត់អោយខ្ញុំទៅរកស៊ីនៅស្រុកគេទៅបែកបាក់ទៅនៅខាងភ្នំពេញនឹងទៅៗនៅស៊ីឈ្នួលគេ
ម្ដាយបែកសុខចិត្តអោយម្ដាយបើកប្រាក់ខែមុនមួយឆ្នាំខ្ញុំអោយគាត់បើកផ្ដាច់(សំលេងរំខានពីខាងក្រៅ)យកមកទាំងអស់ អោយតែម្ដាយបានស្រួល(សំលេងកូនក្មេង)
មួយឆ្នាំខ្ញុំសុខចិត្តធ្វើសុខចិត្តទ្រាំនៅនឹងផ្ទះរបស់គេខ្ញុំធ្វើនៅនឹងផ្ទះរបស់គេនឹងទ្រាំរហូតទាល់តែដាច់លុយរបស់គេបានខ្ញុំវិលមកផ្ទះវិញ(សំលេងស៊ីផ្លេម៉ូតូ)
ហើយខ្ញុំទៅស៊ីឈ្នួលគេនឹងមិនអោយលំប៉េលំបាកមិនដែលថាម្ចាស់គេថាខ្ញុំដើរខិលខូចទៅនេះទៅនោះគឺខ្ញុំអត់ទេៗ
ខ្ញុំថែរក្សាខ្លួនប្រាណរបស់ខ្ញុំណាស់ដើម្បីចិញ្ចឹមម្ដាយរបស់ខ្ញុំរហូតមកដល់សព្វថ្ងៃដល់ពេលមានប្ដីទៀតខ្ញុំក៏ពិបាកទៀតៗប្ដីមានស្រីរហូតប្ដីរបស់ខ្ញុំ(ក្អក)!

ក៖ ចាសអុំ!

ខ៖ មានស្រីរហូតប្ដីរបស់ខ្ញុំនឹងមានស្រីរហូត!

ក៖ ប្ដីរបស់មានឈ្មោះអីដែរទៅអុំ?

ខ៖ ឈ្មោថា ម៉ាក់ឡាំថា(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអុំ!

ខ៖ ម៉ាក់ ឡាំថា!

ក៖ កាលនឹងអុំស្រលាញ់គ្នាដោយចិត្តនឹងចិត្តឬក៏ឪពុកម្តាយជាអ្នកទុកដាក់អោយ?

ខ៖ អត់ទេ អាពតអ្នករៀបចំអោយ!

ក៖ កាលជំនាន់អាពត អូកាលនឹងគេចាប់អោយចឹងម៉ង?

ខ៖ ចាស
បើយើងស្រលាញ់គ្នាចឹងទៅយើងចាប់ដៃគ្នាចឹងទៅដូចថាយើងស្រលាញ់គ្នាស្មគស្មោះចឹងទៅ
អានឹងដល់ពេលដល់ថ្ងៃរៀងការចឹងទៅគេការអោយ១០០គូអីចឹងទៅ(សំលេងរំខានពីខាងក្រៅ
)ជាងមួយគូចឹងទៅក្នុងវត្តចឹងខ្មៅអ៊ូចឹងទៅក្នុងវត្តនឹងខោអាវខ្មៅចឹងទៅស្លៀកពាក់ខោអាវ

!ក៖ អឹម!

ខ៖ ចាស!

ក៖ ចុះដល់ពេលគ្រាន់តែចាប់ដៃគ្នាហើយការម៉ង?

ខ៖ ចាស!

ក៖ សន្មតថាជាប្តីប្រពន្ធហើយហ៎អុំ?

ខ៖ ចាស ជំនាន់អាពតចឹង!

ក៖ អឹម!

ខ៖ ចាសៗ!

ក៖ តែអុំមានកូនក្រោយអាពតទេន៎អុំ?

ខ៖ អឹម! ជាមួយអាពតនឹងមួយនឹងក្រោយ...ជិតចប់អាពតនឹងមួយ កូនពីបងគេនឹង!

ក៖ ចាស!

ខ៖ មីបងគេនឹង!

កៈ ពិបាកណាស់ចឹងកាលនឹងអ៊ុំសម្រាលកូនតាមណាទៅអ៊ុំ?

ខៈ អូនអើយក្រោយឡើងកូនអើយ ធ្វើការទាំងយប់ទាំងថ្ងៃ
យប់ក្រោកពីយប់ម៉ោងបីបម៉ោងបួននឹងចុះយើងមិនក្រោយពីយប់ទៅស្រែ!

កៈ ចាសអ៊ុំ!

ខៈ ហើយពោះធំមិនដើរតាមភ្លឺស្រែមិនរអិលរហូត!

កៈ អូ....អ៊ុំអើយ!

ខៈ ចាសរអិលដួលពព្រឹសពព្រួស(ភាសាតំបន់)តាមភ្លឺស្រែនឹងព្រោះវាពេលយប់ណាស់!

កៈ ចេះអត់អីអ៊ុំន៍?

ខៈ អត់អីទេ
ខ្ញុំខំតែថាអឹម....កូនរបស់ខ្ញុំអត់នៅទេបើខ្ញុំដើរយប់ព្រលប់រអិលដួលចឹង(សំលេងស៊ីផ្លេម៉ូតូ)!

កៈ ចាសអ៊ុំ!

ខៈ គេអោយស្ទូង(សំលេងស៊ីផ្លេម៉ូតូ) ១០អ្នកនឹងអោយហើយមួយហិចតាៗ
ហើយពេលភ្លឺឡើងអោយដកអោយបានមួយផ្លូន(មួយផ្លូនមាន៤០កណ្ដាប់)ទៀតៗ!

កៈ ចាសអ៊ុំ!

ខៈ ដកបានមួយផ្លូន ចងកណ្ដាប់អាកណ្ដាប់គេប៉ុណ្នឹងហ៎? គេយកទៅស្ទូងណាស់!

កៈ ចាសអ៊ុំ!

ខៈ នឹង វាគ្មានអោយយើងបានសំរាកទេ!

កៈ អឹម! ចុះអ៊ុំកាលនឹងសម្រាលកូនតាមឆ្មបឬក៏ពេទ្យ?

ខៈ តាមឆ្មបអឺ...ពេទ្យ អឺ...ឆ្មបពួកតើពួកនេះពួករំដោះពេទ្យនឹង!

កៈ អូ....អ៊ុំអើយ នៅផ្ទះ....

ខៈ យើងនៅនឹងផ្ទះនឹងតើប៉ុន្តែគ្រាន់តែថាពេទ្យនឹងគេទៅដល់នឹងផ្ទះយើងនឹង!

កៈ អឹម! យើងទៅហៅគេហ៎អ៊ុំ?

ខ៖ ចាស!

ក៖ យើងទៅហៅខ្លួនឯងហ៍អ៊ុំ?

ខ៖ ចាស អត់ទេអោយគ្រួសារយើងនឹងទៅហៅឆ្មបមកគេមកបង្កើតនៅនឹងផ្ទះយើងនឹង!

ក៖ អូ...អ៊ុំចាស!

ខ៖ រួចខ្ញុំកូនដំបូងនោះ កើតបាននិយាយទៅកន្លងមួយយប់នឹង!

ក៖ ចាសអ៊ុំ អូ....

ខ៖ បានកើតមក(សំលេងរំខានពីខាងក្រៅ)!

ក៖ ហើយត្រូវចិញ្ចឹមកូនទៀត ប្រាំបួននាក់ទៀតអ៊ុំកូនច្រើនណាស់(សើច)!

ខ៖ ចាស!

គ៖ កូនច្រើនទៀត(សំលេងអ្នកដទៃ)!

ខ៖ (សើច) ប្រាំបួននាក់ រួចខ្ញុំកាលនឹងអាយុ២៥ឆ្នាំនឹង!

ក៖ ចាសអ៊ុំ
ហើយកាលនឹងអ៊ុំមានដូចថាមានការចងចាំអីគេដែលធ្វើអោយអ៊ុំសប្បាយចិត្តជាងគេនៅក្នុងជីវិតរបស់អ៊ុំណាស់អ៊ុំ?

ខ៖ និយាយឡើងពិបាកចិត្តពិបាកណាស់អូន
មានប្ដីក៏ពិបាកដែរខោអាវមិនដែលបានស្លៀកពាក់ល្អនឹងគេទេ
ចាប់តែស្លៀកឡើខ្មៅសំពត់ខ្មៅអាវខ្មៅមិនដែលបានច្រឡំនឹងគេទេ
មានប្ដីហើយនឹងណាស់អត់ហ៊ានទិញទេសុខចិត្តសុំប្ដីទិញ(សំលេងរំខានពីខាងក្រៅ)!

ក៖ អឺម!

ខ៖ រួចមកនេះណាស់ ខ្ញុំអត់មានស្អីទេ (សំលេងរំខានពីខាងក្រៅ)
ខ្ញុំមកបាតដៃទទេរមកពីស្រុកមកកូនប្រាំ!

ក៖ ចាស!

ខ៖ មកតាមប្ដីខ្ញុំគាត់មានម្ដាយនៅនឹងមានគ្រួសារ មកសុំផ្ទះ
សុំគ្រែគេដេកខ្ញុំគ្រែគេដេកៗ(សំលេងកូនក្មេងក្អក) ខ្ញុំដំបូលគេខ្ញុំគ្រែគេបានមួយ
ដេកធ្លាក់កូនធ្លាក់អីនៅនឹងក្រោមគ្រែ ហើយធ្វើកន្លែងនឹងបានដំបូលធំៗនៅខាងក្រោយនឹង!

ក៖ អឺម!

ខ៖ ធ្វើរោងនៅនឹងៗទៅ(សំលេងរំខានពីខាងក្រៅ) ធ្វើរោងនៅត្រង់នឹងហើយអត់មានស្អីនេះ
កាប់អារែងនៃ...ស្មោរយកមកក្រងខ្ទាស់ៗវាចឹងទៅធ្វើជញ្ជាំងៗបាំងនឹង(សំលេងមាន់រងាវ)
រួចនៅពេលយប់ពស់ៗវែក!

ក៖ អូ...អ៊ុំអើយ!

ខ៖ ធំណាស់កូន វានៅក្នុងព្រៃជុំវិញផ្ទះចឹងនឹងណាស់ មិនទាន់មានផ្ទះអញ្ចេកទេ!

ក៖ ចាស នៅតាមបណ្ដោយនឹងទៅក្រោយនឹងធំណាស់មួយអោប
ហើយទៅខ្ញុំធ្វើរោងនៅត្រង់កន្លែងនឹងណាស់(សំលេងយន្តហោះ)
មួយយប់ដំបូងកូនអើយមាន់នឹងវាតែស្រែក រួចប្ដីខ្ញុំថាអឺម....អុចដែលកេះទៅមើលៗ
ហើយចង្រាន្តបាយយើងប៉ុន្នឹងណាស់ហើយទៅទ្រុងមាន់នៅក្រោមចេះ
ដល់តែទៅអុចភ្លើងទៅមើលទៅពស់ៗវែកចឹងមកម៉ង!

ក៖ អឺម!

ខ៖ ចឹងមកម៉ង អើតក មកចឹងមកក៏បាត់ទៅ
មាន់ស្រែកខ្វោកៗ(សំលេងមាន់ស្រែក)នឹងវាស៊ីពងអស់បាត់មួយសារហើយ
ចាសហើយបានយប់ក្រោយទៀតចាសមកលើកក្រោយទៀតខាំអាប៉ុនកំភួនជើងមួយទៀតខាំ
មួយទៀតកំពុងតែឆាកឈ្ងូសនៅក្រោមចឹងនឹងហើយអង្គុយចឹងលើគ្រែអោយកូនដេកចឹងយើង
ទៅយើងក្រាលចឹង(សំលេងមាន់រងាវ) ឆាកៗលឺមាន់ខ្វោក(មាន់ស្រែក)
ទៀតហើយគ្រាន់លឺខ្វោកទៅមើលដល់ពេលទៅមើលអស់មាន់មួយទៀតហើយងាប់មាន់អស់
មួយហើយប្ដីខ្ញុំថាចងហែងយកមកដាក់តាមជញ្ជាំងដាក់ចងតាមជញ្ជាំងចឹងទៅនៅខាងក្រៅចឹ
ងណាស់(សំលេងកូនក្មេង)គោះពន្លត់ភ្លើងដេកមួយសន្ទុះលឺខរៗ(សំលេងពស់វែក)
ដល់ពេលដែលបើកទ្វាមើលវានៅសណ្ដូកតាមទ្វានឹងណាស់ស៊ីមាន់នឹង(សំលេងឆ្កែព្រូស)វាម
កស៊ីមាន់មួយនឹង(សំលេងឆ្កែព្រូស)

វាមកស៊ីមាន់មួយនឹងដល់តែនេះអត់ហ៊ានវ៉ៃ(ប្តីគាត់មិនហ៊ានវ៉ៃពស់) ក៏ទៅហៅអ្នកជិតខាងអោយគេមកជួយ!

កៈ ចាស!

ខៈ ទៅជួយចាប់បាន ពស់វែកកូនអើយប៉ុននេះ(សំលេងឆ្កែព្រួស)!

កៈ អឹម!

ខៈ ចាប់បាន ពិបាកណាស់ជិវិតខ្ញុំ រួចពេលដែលខ្ញុំឆ្លងទន្លេមិនដែលបាន(សំលេងមាន់រងាវ)ស្អីស៊ីទេកូន(សំលេងមាន់រងាវ) ប្តីរបស់ខ្ញុំកូនមួយនឹងប្តីរបស់ខ្ញុំគាត់ទៅធ្វើការក្រចេះស្ទឹងត្រែងៗឆ្លងទន្លេមីបងមួយៗ អត់មានស្អីសោះបានបងប្អូនអ្នកដែលនៅជិតខាងគេមកជួយៗចឹងទៅអ្នកខ្លះគេទិញនេះទិញ នោះយកមកអោយអ្នកខ្លះទៅអ្នកខ្លះទៅគេទិញធ្យូងទិញអីយកមកអោយចឹងទៅក៏បានដុត ទៅណាស់!

កៈ ចាស!

ខៈ ចាស!

កៈ ចុះផ្ទះនឹង(សំលេងមាន់រងាវ)អ៊ុំធ្វើខ្លួនឯងឬក៏ជួលជាងគេមកធ្វើដែរអ៊ុំ?

ខៈ ប្តីខ្ញុំធ្វើខ្លួនឯង!

កៈ  គាត់ធ្វើសាងសង់ក្នុងម៉ូតអីដែរអ៊ុំ?

ខៈ នឹងធ្វើផ្ទះនឹង!

កៈ ចេះតែប្រក់ៗទៅហ៏អ៊ុំ!

ខៈ ចាស!

កៈ ចេះតែប្រក់ៗចឹងទៅន៏អ៊ុំ? សន្សំបន្តិចម្តងៗចឹងទៅន៏អ៊ុំ?

ខៈ ចាស សន្សំម្តងបន្តិចៗចឹងទៅ!

កៈ ចុះអ៊ុំកាលនឹងអ៊ុំប្រុសហើយនឹងអ៊ុំស្រីធ្វើការងារអីដែរដើម្បីនឹងប្រកបរបរចិញ្ចឹមជីវិត?

ខ៖ ដំបូងមកដល់គាត់ស៊ីឈ្នួលគេ(មានសំលេងរំខានពីខាងក្រៅ)
ស៊ីឈ្នួលគេធ្វើចំការធ្វើអីនឹងណាស់ស៊ីឈ្នួលគេមួយថ្ងៃៗប៉ុណ្ណឹងៗទៅណាស់ហើយខ្ញុំនៅផ្ទះនឹងឆាកឈូសទៅ អឺម...ហើយដល់នេះទៅរួចទៅគាត់ដើរធ្វើកាណូតៗ!

ក៖ ចាស!

ខ៖ ធ្វើកាណូតទៅចាស
ធ្វើកាណូតចឹងទៅខ្ញុំនៅផ្ទះចឹងទៅក៏ចេះតែឆាកឈូសចឹងទៅគ្រាន់បានហូប!

ក៖ ចាស ដើម្បីនឹងគ្រាន់បានចិញ្ចឹមជីវិតន៍អ៊ុំ(សំលេងរំខានពីខាងក្រៅ)?

ខ៖ ចាស ដើម្បីចិញ្ចឹមជីវិតនាំគ្នាចេះតែធ្វើទៅ(សំលេងរំខានពីខាងក្រៅ)
ដល់នេះទៅបង្វាស់គោគេក៏បានគោនឹងមួយបានគោមួយចឹងទៅគោនឹងក៏ត្រូវបានលក់ទៅដល់ពេលបានលក់នឹងក៏បានលុយសន្សំទៅបានទិញម៉ូតូៗបានប្តីរត់
យកទៅរត់ធ្វើការហើយនឹងរថដ៏(សំលេងរំខានពីខាងក្រៅ)ដល់តែសន្សំៗទៅទិញមេសេះបានមួយ!

ក៖ អូ...អ៊ុំទិញសេះ!

ខ៖ ចាស ទិញមេសេះបានមួយ
អោយប្តីរថម៉ូតូឌុបទៅហើយខ្ញុំនឹងកូនប្រុសអាបងអាទីពីរនឹងកាប់ដីទៅកាប់ដីដាក់លក់នៅតាមផ្ទះរបស់គេចឹងណាស់
ខ្ញុំកាប់ពីរនាក់កូនចឹងទៅហើយខ្ញុំបរដាក់នៅតាមផ្ទះរបស់គេចឹងទៅបរតែខ្លួនឯងនឹង
បរនឹងរទេះសេះនឹងខ្លួនឯង!

ក៖ កាលនឹងដីមួយរទេះនឹងបានប៉ុន្មានដែរអ៊ុំ?

ខ៖ មួយរទេះបាន(សំលេងរំខានពីខាងក្រៅ) កាលនឹងបានមួយពាន់ពីរពាន់នឹង!

ក៖ យើងកាប់ពីណាមកវិញទៅអ៊ុំស្រី?

ខ៖ កាប់ជួលយើងទិញដីរបស់គេចឹងទៅ(សំលេងរំខានពីខាងក្រៅ)
ដូចថាមួយកន្លែងចឹងប៉ុន្មានដូចថាមួយកន្លែងមួយជីពីរជីចឹងទៅយើងទិញគេយកដីកាប់ទៅយកដីកាប់ដាក់នៅតាមផ្ទះរបស់គេចឹងទៅ(សំលេងរំខានពីខាងក្រៅ)!

ក៖ អឺម! ចឹងអ៊ុំមិនមែនមានតែដីតែមួយកន្លែងនឹងទេអ៊ុំមានដីច្រើន?

ខ៖ 
អត់មែនទេអ៊ុំមានតែមួយកន្លែងទេប៉ុន្តែគ្រាន់តែថាយើងទិញគេគ្រាន់ទិញយកមកកាប់ដីនឹងណាស់!

ក៖ អ៎....

ខ៖ 
នឹងហើយដីៗនឹងជារបស់គេទេប៉ុន្តែគ្រាន់តែថាយើងទិញយកមកកាប់ដីយើងមកកាប់បាននឹងរួចហើយម្ចាស់គេនឹងយកដីរបស់គេទៅវិញទៅ!

ក៖ ចាសអ៊ុំ!

ខ៖ ចាស(សំលេងរំខានពីខាងក្រៅ)!

ក៖ 
នៅក្នុងរយៈពេលប៉ុន្មានអីប៉ុន្មានចឹងទៅយើងទៅនិយាយជាមួយគេចឹងទៅ(សំលេងរំខានពីខាងក្រៅ)?

ខ៖ ចាស ដូចដីអូរនេះយើងកាប់ទៅ
បើដូចដីនេះកាប់អត់បានទេយើងទិញគេទៅដីអូរនេះនឹងទឹកនឹង(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាស!

ខ៖ ដីនឹងអូរទឹកនឹង(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាស បានមួយរទេះតែមួយពាន់នឹងទេអ៊ុំ?

ខ៖ មួយពាន់ ជូនកាលទៅបានតែប្រាំរយផង!

ក៖ អូ....បានតិចចឹងនៅក្នុងមួយថ្ងៃអ៊ុំរកបានប៉ុន្មានទៅកាលនឹង?

ខ៖ បានម្ភៃរទេះអីចឹងទៅ!

ក៖ បានពីរម៉ឺនអីដែរន៏?

ខ៖ ចាស បានប៉ុន្នឹង យើងហូបតិចតួចទៅណាស់!

ក៖ ម្ភៃរទេះបើគិត(សំលេងរំខានពីខាងក្រៅ) ទៅអ៊ុំធ្វើតាំងពីព្រឹកទល់ល្ងាចហ៎អ៊ុំ?

ខ៖ ចាសធ្វើតាំងពីព្រឹកទល់ល្ងាចម៉ង
គ្រាន់តែបានមកបាយទឹកនៅនឹងផ្ទះហើយដល់ម៉ោងចុះទៅទៀតហើយ
ចាសមកដល់នឹងដាំបាយដាំទឹកព្រួសប្រាស់ចឹងទៅបាយហើយអីហើយនឹងកប្រញាប់ប្រញាល់
ទៅវិញទៅជាមួយកូនរបស់ខ្ញុំនឹង!

ក៖ ចាសៗអ៊ុំ
ចាសចឹងអ៊ុំមានការតស៊ូមែនទែននៅក្នុងជីវិតរបស់អ៊ុំស្រី(សំលេងរំខានពីខាងក្រៅ)!

ខ៖ ចាស!

ក៖ ចឹងអ៊ុំដូចថាតាមអី...ជីវិតរបស់អ៊ុំមានការតស៊ូនឹងធ្លាប់បនឆ្លងនូវបទពិសោធន៍ច្រើនចឹង
អ៊ុំមានពាក្យពេចន៍អីជាចុងក្រោយដើម្បីជាការផ្តែផ្តាំជាពិសេសទៅដល់កូនចៅជំនាន់ក្រោយ
អោយគេបានស្តាប់ណាស់អ៊ុំ?

ខ៖ ចាសចឹងខ្ញុំចេះតែ(សំលេងស៊ីផ្លេម៉ូតូ) ណែនាំទៅដល់កូនចៅជំនាន់ក្រោយនឹងថា
កូនអើយម្តាយគ្មានកេរ្តិ៍អាករទុកអោយពួកកូនទេណាស់
មានតែប្រឹងដោយខ្លួនឯងទេមើលគំរូម្តាយចុះណាស់
ម្តាយអត់មានអីទេម្តាយមកស្រុកគេនឹងដៃទទេរតែឆ្នាំងតែចាននឹងក៏គ្មានផង
បានម្តាយ...ឪពុកទេទៅធ្វើការលោកជំពុះក្អែកទេអោយ
លោកតាជំពុះក្អែកអោយតាំងពីកន្ទេល តាំងពីខ្មើយ
តាំងពីចានឆ្នាំងឡើង(សំលេងរំខានពីខាងក្រៅ)
អឺម...រួចម្ចាស់ទូកដរថសព្វថ្ងៃនេះម្ចាស់ទូកដរព្រែកលាបនេះប្តីខ្ញុំទៅធ្វើកាណូតនឹង
គេអោយម៉ាគ្រឿងខ្ទមដូចថាមួយគ្រឿងផ្ទះអាចបញ្ចូលគោបានណាស់ផ្ទះកាំជណ្តើរបី
កាំជណ្តើរបួននឹងណាស់គេអោយមកមួយគ្រឿងល្មមនឹងអាចធ្វើផ្ទះបាននៅណាស់!

ក៖ អឺម!

ខ៖ ចាស គាត់អោយមកនៅ!

ក៖ ចាស!

ខ៖ គាត់អោយមកធ្វើនៅចុះ គេអាណិតគេមានធម្មមេត្តាមកដល់យើង
ចាស(សំលេងស៊ីផ្លេម៉ូតូ)
គ្រាន់តែធ្វើផ្ទះហើយមិនទាន់នឹងរួចស្រួលបួលចឹងទៅម្តាយខ្ញុំអ៎...ម្តាយក្មេកខ្ញុំនឹងធ្វើហើយផ្ទះ

ស្រួតៗ(ម្តាយក្មេករបស់គាត់ប្រញាប់ដេញគាត់អោយចុះទៅនៅនឹងផ្ទះដែលគាត់បានធ្វើនឹង) ចុះទៅនៅនឹងផ្ទះនឹងទៅនឹងម្តាយក្មេក!

ក៖ ចាសអ៊ុំ ចឹងអ៊ុំមានពាក្យអីដែរឬទេអ៊ុំ? ដើម្បីផ្តាំផ្ញើរ....

ខ៖ ចាសៗ ខ្ញុំគ្មានពាក្យពេចន៏អីច្រើនទេ គ្រាន់តែថាចង់ផ្តែផ្តាំទៅដល់កូនរបស់ខ្ញុំនាស់ជាចុងក្រោយទៅដល់របស់កូនរបស់ខ្ញុំនឹងណាស់ ថាកុំមកទាមទារម្តាយៗគ្មានអីទេមានតែដីមួយដុំនឹងទេ កូនឯងប្រឹងរកស៊ីទៅណាស់(សំលេងម៉ូតូ) តស៊ូខ្លួនឯងដើម្បីចិញ្ចឹមជីវិតខ្លួនឯងនឹងទៅណាស់ ម្តាយឯងឯណោះក៏ប្រឹងដោយខ្លួនឯងដែរទេកូន!

ក៖ ចាសអ៊ុំស្រី!

ខ៖ ម្តាយផ្តាំកូនចឹងណាស់កូន មានតែប៉ុណ្នឹងទេកូន!

ក៖ ចាសត្រូវហើយអ៊ុំ!

ខ៖ កុំមកទាមទារម្តាយណាស់(សំលេងរំខានពីខាងក្រៅ) ម្តាយមានដីតែមួយកន្លែងនឹងទេ បើថាកូនឯងមកស្នាក់នៅរកស៊ីអីកូនឯងមកស្នាក់នៅចុះ បើថាចែកអោយដាច់ៗតែម្តងនោះកូនប្រាំបួននាក់បើកាត់ចែកគ្នាទៅបានប៉ុន្មានម្នាក់ មិនបាននឹងមួយម៉ែត្រម្នាក់ផងបណ្តោយប៉ុណ្នឹងទទឹងប៉ុណ្នឹង!

ក៖ ចាសត្រូវហើយអ៊ុំ!

ខ៖ ចាស ចឹងបានខ្ញុំ(សំលេងរំខានពីខាងក្រៅ) ដីត្រង់នឹងទុកអោយមីកូនពៅកូនទីពីរនឹងដែលគ្នាលំបាកប្តីប្រពន្ធណាស់ដូចថាមានប្តីមានប្រពន្ធវាបែកបាក់គ្នាអីចឹងទៅអាណិតគ្នាអោយវានៅពីរនាក់បងប្អូនអីចឹងចុះណាស់ យើងមានប្តីមានគោលដៅហើយយើងប្រឹងរកស៊ីដោយខ្លួនឯងចឹងទៅ!

ក៖ ចាសអ៊ុំ!

ខ៖ អាណិតប្អូន ព្រោះយើងគ្មានអ្នកណានឹងទីពឹងមានតែម្តាយហើយម្តាយគ្មានវិញគ្មានអ្នកណាទេមកស្រុកគេ (សំលេងស៊ីផ្លេឡាន) នឹងក្បាលមួយតែឯងទេ ម្នាក់អោយគត់

មានបងប្អូនមកពីណាអត់មានទេខ្ញុំមកតែម្នាក់ទេនៅនឹងស្រុកនឹង(សំលេងរំខានពីខាងក្រៅ)អត់មានបងប្អូនញ្ញាតិសន្តានអីទេ!

ក៖ អឹម!

ខ៖ ខ្ញុំមករស់នៅនឹងមានតែម្នាក់ឯងនឹងទេណាស់កូន!

ក៖ ចាសអ៊ុំ!

ខ៖ ខ្ញុំមានតែម្នាក់ឯងគត់គ្មានបងប្អូនសាច់ញ្ញាតិឯណាទេ
មានតែទីពឹងបងប្អូនអ្នកជិតខាងនឹងចាត់ទុកដូចតែបងប្អូនចឹងណាស់!

ក៖ ចាសអ៊ុំ!

ខ៖ ចឹងអ៊ុំមានតែប៉ុណ្ណឹងទេន៍អ៊ុំ?

ខ៖ ចាស!

ក៖ ចាសអ៊ុំ!

ខ៖ ពិបាកវេទនាណាស់កូនអើយ
នៅពេលដែលខ្ញុំកូនខ្ចី(ពេលដែលអ៊ុំស្រីទើបតែសម្រាលកូនប្តីរបស់គាត់មិនបាននៅទេ)ប្តីមិននៅអត់មានអីស៊ីនៅពេលឆ្លងទន្លេអត់មានបាយហូប(សំលេងម៉ូតូរំខាន)
មានបាយតែមួយល្មមមួយដុំចែកកូនបន្តិចម្នាក់ចឹងទៅ
យប់នឹងម្តាយឈឺពោះឆ្លងទន្លេ(សំលេងរំខានពីខាងក្រៅ)ណាស់!

ក៖ ចាសអ៊ុំ!

ខ៖ ឈឺពោះឆ្លងទន្លេ បានបងប្អូនអ្នកនៅជិតខាងគេជួយនេះបន្តិចនោះបន្តិចទៅ!

ក៖ ចាសអ៊ុំ!

ខ៖
រួចទៅដល់ពេលបាយហូបគ្មានអីហូបបាយជាមួយនឹងបាយទេមានតែទឹកក្តៅស្រូបបាយហើយនឹងអំបិលនឹងទៅ!

ក៖ ចាសអ៊ុំស្រី!

ខ៖ ចឹង....

ក៖ ប៉ុន្តែបានសុខភាពរបស់ខ្ញុំនឹងល្អចេះដូចចថាអត់មានទាស់អីទេ ចេះអត់មានអីដែរណាស់ ហើយពេលដែលនៅលើចង្ក្រាននឹងខ្ញុំដើរទៅគក់កន្ទបរបស់កូននឹងខ្លួន ឯងនៅឯអូរឯណោះនៅនឹងអូរនោះ អូរកាលពីមុននឹងអត់មែនគគ្រិចអញ្ចឹងទេពីមុនស្អាតណាស់យើងទៅងូតទឹកងូតអីនៅនឹងទៅណាស់(សំលេងរំខានពីខាងក្រៅ) ស្អាតណាស់កន្លែងនឹងហើយគេៗឃើញខ្ញុំចឹងគេថាង៉ែងៗនៅលើចង្រានន្តង៉ែងចុះទៅណាដាច់ខ្សែ អឹ...ដាច់សីមាដាច់អីអស់ហើយ(សំលេងរំខានពីខាងក្រៅ) ខ្ញុំអត់មានអ្នកគត់អោយខ្ញុំហើយកូននៅតូចៗមិនដឹងថាទៅទីពឹងអ្នកណាជូនកាលឃ្លានបាយខ្លាំងទៅយំក៏មានដែរ(សំលេងរំខានពីខាងក្រៅ) កូនខ្ញីធម្មតាយើងហេរយើងហាត់ចឹងណាស់!

ក៖ ចាសអ៊ុំស្រី!

ខ៖ គ្មានអីនឹងហូប(សំលេងរំខានពីខាងក្រៅ) ចឹងណាស់បានថា ប្រវត្តិខ្ញុំវាហួសពីល្វីងជូរចត់ណាស់កូនអើយលំបាកមហាសែនលំបាកហើយ!

ក៖ ចាសអ៊ុំស្រី
ចុះអ៊ុំកាលអ៊ុំនៅពីតូចអ៊ុំមានក្តីស្រម៉ៃចង់ធ្វើជាអីដែរនៅពេលដែលធំឡើងណាស់?

ខ៖ កាលពីតូចខ្ញុំស្រម៉ៃថា បើសិនជាខ្ញុំបានរកស៊ីមានបាន ខ្ញុំស្រម៉ៃថាបើពេលដែលបានប្តីចឹងទៅកាត់កបទៅ កុំអោយប្តីធ្វើនឹងគេបាបកុំអោយប្តីធ្វើអីចឹងទៅណាស់ ដល់តែពេលបានប្តីហើយ គេមានស្រីរហូត គេមិនវ៉ៃមិនជំអីទេតែគេមានស្រីរហូត ជូនកាលទៅធ្វើកាណូតចឹងបីខែនឹងគេគ្មានមកកផ្ទះទេអើតយើងទេគេនៅនឹងៗរហូតទាល់តែហើយកាណូតបានគេមក ហើយខ្ញុំពោះធំទៀត(មានផ្ទៃពោះ) អត់រកអីធ្វើបានបានអីស៊ី ជូនកាលទៅសុំម្តាយចឹងទៅគេអោយដើមអង្ករមួយថ្ពិលប៉ុន្នឹងយកមកបុកទៅបបរអោយកូនស៊ី ជូនកាលទៅកូនប្រាំបីប្រាំបួននាក់នឹងហូបបបរមួយកំប៉ុង ដាក់បបរអង្ករមួយកំប៉ុងអោយកូនស៊ី(សំលេងរំខានពីខាងក្រៅ) ប៉ុន្តែជំនាន់នោះខ្ញុំគ្មានទៅជំពាក់អ្នកណាមួយរយទេ អត់ហ៊ានខ្ចីគេទេមានមួយពាន់ខ្ញុំទិញពាន់មានកន្លះគីឡូខ្ញុំទិញកន្លះគីឡូ ខ្ញុំគ្មានទិញជៀរបុលគេទេមានប៉ុន្មានហូបប៉ុណ្ណឹងទៅ!

កៈ ចាសៗ អរគុណអ៊ុំច្រើនអ៊ុំ ដែលអ៊ុំអឺ...បាន(សំលេងរំខានពីខាងក្រៅ) ប្រាប់នៅបទពិសោធន៍របស់អ៊ុំក៏ដូចជាអឺ...ជីវិតរបស់អ៊ុំដែលបានឆ្លងកាត់ពីមុនមកនឹងពីប្រវត្តិរបស់អ៊ុំស្រីណាស់អ៊ុំ
ចឹងខ្ញុំសូមអរគុណអ៊ុំច្រើនមែនទែនដែលបានចំណាយពេលអោយក្មួយសំភាសន៍ណាស់អ៊ុំ ហើយអ៊ុំចង់បន្ថែមពាក្យពេចន៍អីដែរឬទេអ៊ុំ? ឬក៏មានអស់ហើយអ៊ុំ?

ខៈ ដូចជាគ្មានពាក្យអីទៀតទេកូន!

កៈ ចាស នឹងហើយអរគុណអ៊ុំច្រើនថ្ងៃនឹង!

ខៈ ចាស!

កៈ ចាសចឹងខ្ញុំសូមបញ្ជាក់ថាសំលេងរបស់អ៊ុំនឹងត្រូវបានយកទៅ(សំលេងរំខានពីខាងក្រៅ) Post នៅក្នុងវេបសាយរបស់ខាងសាលាសហរដ្ឋអាមេរិចណាស់អ៊ុំ!

ខៈ ចាសៗ!

កៈ ចឹងអ៊ុំអនុញ្ញាតអោយខាងសាលាយកសំលេងអ៊ុំទៅPost ដែរឬអ៊ុំ(មានសំលេងរំខានពីខាងក្រៅ)?

ខៈ យកចុះអត់អីទេកូន!

កៈ ចាសអរគុណច្រើនអ៊ុំ ចាសសុខសប្បាយអ៊ុំ!

ខៈ ចាស!

កៈ ចាសអ៊ុំសូមជំរាបលាអ៊ុំ ហើយសូមជូនពរអោយក្រុមគ្រួសារនឹងអ៊ុំមានសុខភាពល្អនឹងមានសុភមង្គលក្នុងក្រុមគ្រួសារណាស់អ៊ុំ!

ខៈ ចាស!

កៈ ចាសអរគុណច្រើនអ៊ុំ!